ព្រះរាជាណាចក្រកម្ពុជា

KINGDOM OF CAMBODIA

ជាតិ សាសនា ព្រះមហាក្សត្រ

Nation Religion King

# <u>កិច្ចព្រមព្រៀងសះជាលើករណីដីចម្ការកៅស៊ូគ្រួសារ</u>
# <u>របស់សហគមន៍ភូមិពូចាជាមួយក្រុមហ៊ុនវ៉ារ៉ាណាស៊ី</u>

# <u>Settlement Agreement on Family Rubber Farmland of Pu Char Village with Varanasi Company</u>

កិច្ចព្រមព្រៀងនេះធ្វើនៅស្រុកពេជ្រាដា ខេត្តមណ្ឌលគិរី, នាថ្ងៃទី២០.. ខែ.កញ្ញា....ឆ្នាំ២០២១

This Agreement is entered into Pichreada District, Mondulkiri province, on the 20th.....Sep. 2021

**រវាង**

**Between**

ភាគីតំណាងសហគមន៍លើករណីដីចម្ការកៅស៊ូគ្រួសាររបស់សហគមន៍ភូមិពូចា រួមមាន៖

The community party representing the family rubber farmland of Pu Char village includes:

ប្រប់ ទុច

១).ឈ្មោះ ~~ប្រាក់ ប៊ុនញ៉ុង~~ ភេទ ប្រុស កើតឆ្នាំ[redacted]មានតួនាទីជា តំណាងសហគមន៍

Brop Tuch

1. ~~Prak Bonnhong~~, male, born in[redacted]ommunity representative

២).ឈ្មោះ ព្យើស ញែប ភេទ ប្រុស កើតឆ្នាំ [redacted]មានតួនាទីជា តំណាងសហគមន៍

2. Pcheus Nheb, male, born in [redacted], community representative

៣). ឈ្មោះ ព្រុត ថាភេទ ប្រុស កើតឆ្នាំ [redacted] មានតួនាទីជា អនុប្រធានសហគមន៍

3. Prut Tha, male, born in [redacted], as the Deputy Leader of community

មានទីលំនៅបច្ចុប្បន្ននៅភូមិពូចា ឃុំប៊ូស្រា ស្រុកពេជ្រាដា ខេត្តមណ្ឌលគិរី ហៅកាត់ថា "**ភាគីសហគមន៍**" ។

Currently residing in Pu Char village, Busra commune, Pichreada district, Mondulkiri province, referred to as "**The Community Party**".

**ក្រុមហ៊ុនវ៉ារ៉ាណាស៊ី** តំណាងដោយ លោក[redacted]កើតឆ្នាំ[redacted]កាន់លិខិតឆ្លងដែនលេ[redacted] ចុះថ្ងៃទ[redacted] ចេញឱ្យដោយប្រទេស[redacted] និង កញ្ញា[redacted]កើតឆ្នាំ[redacted] កាន់លិខិតឆ្លងដែនលេខ[redacted] ចុះថ្ងៃទី[redacted]ចេញឱ្យដោយប្រទេ[redacted] មានអាសយដ្ឋានក្រុមហ៊ុនស្ថិតនៅផ្ទះលេ[redacted] ផ្លូវលេ[redacted]ក្រុម[redacted] សង្កា[redacted] ខណ្ឌ[redacted]ដែលជាភាគីវិវាទហៅកាត់ថា "**ភាគីក្រុមហ៊ុន**" ។



first class
in pursuit of speed and quality

**First-Class Solutions Ltd.,** registered under No. Co. 13113/09P with the Ministry of Commerce of the Kingdom of Cambodia

#12 Street 222, Phnom Penh, Cambodia
+855 23 214 142 / 12 925 789 / 18 960 748 / 78 567 863
fcinfo@firstclass.com.kh | www.firstclass.com.kh
(IMG2021)

Phnom Penh, September 17, 2021
*This is to certify that this translation correctly corresponds to all the essential particulars of the attached document, but does not establish the authenticity of the original document or the correctness of the contents therein.*

FIRST-CLASS SOLUTIONS LTD.

**CHAN Sopheap**, Translation Dept. **LIM Kruy**, CEO

**Varanasi Co., Ltd.**, represented by [redacted] born in [redacted], holding Passport No. [redacted] issued on [redacted] by [redacted] and [redacted], born in [redacted], holding Passport No [redacted] issued on [redacted] by [redacted], with the company's address at House [redacted] street [redacted], group [redacted] village [redacted] quarter, [redacted] District, [redacted] as disputing party referred to as "**The Company Party**".

**ភាគីទាំងអស់បានព្រមព្រៀងគ្នាដូចតទៅ៖**

**The Parties agreed to the following:**

**ប្រការ ១.-កម្មវត្ថុនៃកិច្ចព្រមព្រៀង**

**Article 1.- Subject of the Agreement**

១.១.- ភាគីសហគមន៍ និងភាគីក្រុមហ៊ុន យល់ព្រម និងឯកភាពគ្នាលើចំណុចសះជារួមគ្នាមួយចំនួនដូចខាងក្រោមនេះ៖

**1.1.- The Community Party** and **the Company Party** agree and approve the common settled issues as below:

**១.១.១.-ករណីផ្លូវចូលទៅចម្ការកៅស៊ូគ្រួសារ**

**1.1.1.- Road access to family rubber farmland**

- ភាគីក្រុមហ៊ុនឯកភាពជួសជុលផ្លូវ មួយរយ(១០០) ម៉ែត្រ នៅក្នុងដែនសម្បទានដីសេដ្ឋកិច្ច និងផ្លូវជុំវិញក្នុងសម្បទានដីសេដ្ឋកិច្ចដែលភាគីសហគមន៍បានបង្ហាញ ប៉ុន្តែភាគីក្រុមហ៊ុនមិនទទួលជួសជុលផ្លូវខាងក្រៅដែនសម្បទានដីសេដ្ឋកិច្ចរបស់ក្រុមហ៊ុនឡើយ។
- The **Company Party** agrees to repair a one hundred (100) meters road inside the boundary and the road surrounding the economic land concession which is to be shown by the **Community Party**, but the **Company Party** could not repair the road outside economic land concession.
- ភាគីក្រុមហ៊ុនយល់ព្រមមិនបិទផ្លូវ ហើយភាគីសហគមន៍ឯកភាពឱ្យអ្នកយាមផ្លូវរបស់ក្រុមហ៊ុនធ្វើការត្រួតពិនិត្យ និងសួរនាំនៅពេលឆ្លងកាត់ ចេញនិងចូលទៅចម្ការកៅស៊ូគ្រួសារ។
- The **Company Party** agrees not to close the road and the **Community Party** agrees that the guard of company can check and ask something before entrance and exit to the family rubber farmland.
- ភាគីក្រុមហ៊ុននឹងធ្វើការជួសជុលផ្លូវ មួយ (១) ឆ្នាំម្តង (នៅពេលត្រូវការ) ក្នុងតំបន់សម្បទានដីសេដ្ឋកិច្ច។
- The **Company Party** shall repair the road 1 (one) time (when needed) every year in the economic land concession areas.
- ករណីភាគីក្រុមហ៊ុនរកឃើញថាមានសមាជិកសហគមន៍ធ្វើឱ្យខូចខាតផ្លូវដោយប្រើច្រវ៉ាក់ភ្ជាប់នឹងម៉ូតូ ឬរថយន្តភាគីក្រុមហ៊ុននឹងរាយការណ៍ទៅតំណាងសហគមន៍ទាំង ៤ ភូមិ ព្រមទាំងធ្វើការដោះច្រវ៉ាក់ចេញពីយានយន្តទាំងនោះ។
- In case the **Company Party** finds that any community member has damaged the road by using chain attached with motorbikes or cars, the **Company Party** shall report to the representatives of 4 villages as well as remove those chains from the vehicles.



first class
in pursuit of speed and quality

**First-Class Solutions Ltd.**, registered under No. Co. 13113/09P with the Ministry of Commerce of the Kingdom of Cambodia

#12 Street 222, Phnom Penh, Cambodia
+855 23 214 142 / 12 925 789 / 18 960 748 / 78 567 863
fcinfo@firstclass.com.kh | www.firstclass.com.kh
(IMG2021)

Phnom Penh, September 17, 2021
*This is to certify that this translation correctly corresponds to all the essential particulars of the attached document. It does not establish the authenticity of the original document or the correctness of the contents herein.*

FIRST-CLASS SOLUTIONS

CHAN Sopheap, Translation PM    LIM Kruy, CEO

- ភាគីសហគមន៍យល់ព្រមធ្វើការជួបប្រជុំតាមរយៈអ្នកតំណាងសហគមន៍ទាំង៤ភូមិ លើករណីខូចខាតផ្លូវនេះ។
- The **Community Party** agrees to have meetings with representatives of the 4 villages to discuss about the damaged road.
- ភាគីសហគមន៍យល់ព្រមធ្វើការណែនាំដល់សមាជិកសហគមន៍ដែលធ្វើឱ្យខូចខាតផ្លូវទាំងនោះ។
- The **Community Party** agrees to educate their members about how to take care of the road and root cause damage the road.

១.១.២.-ការដោះដូរទីតាំងដីចម្ការកៅស៊ូគ្រួសារ និងការបញ្ចប់កិច្ចសន្យាដីចម្ការកៅស៊ូគ្រួសារ

**1.1.2.- Changing the location and end of contract agreement of family rubber farmlands**

- ភាគីសហគមន៍ និងភាគីក្រុមហ៊ុន ព្រមព្រៀងគ្នាដូចខាងក្រោម៖
- The **Community Party** and **Company Party** agree as follows:
  - ការបញ្ចប់កិច្ចសន្យាចម្ការកៅស៊ូគ្រួសាររវាងក្រុមហ៊ុន និងសហគមន៍ ត្រូវទូទាត់តម្លៃដែលបានអភិវឌ្ឍនៅលើដីទៅតាមតម្លៃទីផ្សារ ធ្វើឡើងដោយការស្ម័គ្រចិត្ត និងមិនមានការបង្ខិតបង្ខំពីភាគីណាមួយឡើយ។
  - Ending the contract agreement of family rubber farmland between the company and the community is based on the market price of the development on the land, and on a voluntarily basis and without coercion from any party.
  - ការដោះដូរទីតាំងដីចម្ការកៅស៊ូគ្រួសារធ្វើឡើងដោយការស្ម័គ្រចិត្ត និងមិនមានការបង្ខិតបង្ខំពីភាគីណាមួយឡើយ។
  - Changing the location of family rubber farmland shall be on a voluntarily basic and without coercion from any party.
- សហគមន៍ត្រូវធ្វើការជូនដំណឹងអំពីការបញ្ចប់កិច្ចសន្យាដីចម្ការកៅស៊ូគ្រួសារ ឬការដោះដូរទីតាំងដីចម្ការកៅស៊ូគ្រួសារ ជាមួយក្រុមហ៊ុន ទៅតំណាងសហគមន៍របស់ខ្លួនដោយខ្លួនឯងផ្ទាល់ជាមុន។
- The communities shall inform their representatives themselves of the ending of the contract agreement of family rubber farmland or changing the location of family rubber farmland.

- ការជូនដំណឹងនេះធ្វើឡើងសម្រាប់តែសមាជិកសហគមន៍ដែលមានឈ្មោះនៅក្នុងការសម្រុះសម្រួល និងចរចារវាងសហគមន៍ និងក្រុមហ៊ុនតែប៉ុណ្ណោះ។
- The notification shall be made only for community members who are in the mediation and negotiation process with the company.
- ភាគីក្រុមហ៊ុនមិនមានកាតព្វកិច្ចក្នុងការជូនដំណឹងអំពីការបញ្ចប់កិច្ចសន្យា ឬដោះដូរទីតាំងដីចម្ការកៅស៊ូគ្រួសារ ទៅតំណាងសហគមន៍ឡើយ។
- The **Company Party** has no obligation to inform representatives of the community of the ending of the contract agreement of or changing of the location of family rubber farmland.



first class
in pursuit of speed and quality
**First-Class Solutions Ltd.**, registered under No. Co. 13113/09P with the Ministry of Commerce of the Kingdom of Cambodia
#12 Street 222, Phnom Penh, Cambodia
+855 23 214 142 / 12 925 789 / 18 960 748 / 78 567 863
fcinfo@firstclass.com.kh | www.firstclass.com.kh
(IMG2021)
Phnom Penh, September 17, 2021
*This is to certify that this translation correctly corresponds to all the essential particulars of the original document. It does not establish the authenticity of the original document or the correctness of its contents herein.*
CHAN Sophea, Translation PM    LIM Kruy, CEO

### ១.១.៣.-ទំហំដីចម្ការកៅស៊ូគ្រួសារ និងទិន្នន័យដីចម្ការកៅស៊ូគ្រួសារ

### 1.1.3.- Size and data of family rubber farmland

ភាគីក្រុមហ៊ុន និងភាគីសហគមន៍ ព្រមព្រៀងលើទំហំដីចម្ការកៅស៊ូគ្រួសារដែលបានកាន់កាប់ជាក់ស្តែងក្នុងកិច្ចសន្យាចុងក្រោយរវាងក្រុមហ៊ុន និងសហគមន៍ និងយោងទៅតាមទិន្នន័យនៃទំហំដីចម្ការកៅស៊ូគ្រួសារដែលផ្តល់ឱ្យដោយក្រុមហ៊ុន។

The **Company Party** and **Community Party** agree on the size of family rubber farmland as indicated in the latest contract between the company and the community as well as based on the data of family rubber farmland which is provided by the company.

#### ១.១.៣.១.-ទំហំដីចម្ការកៅស៊ូគ្រួសារ

#### 1.1.3.1.- Size of family rubber farmland

- ភាគីក្រុមហ៊ុនយល់ព្រមដាក់ទំហំដីចម្ការកៅស៊ូគ្រួសារដែលមាននៅក្នុងកិច្ចព្រមព្រៀងបច្ចុប្បន្នទៅក្នុងកិច្ចសន្យាថ្មីដែលនឹងបង្កើតឡើងនាពេលអនាគត ។
- The **Company Party** agrees to put the size of the family rubber farmland indicated in the current agreement into the new agreement which will be entered into in the future.
- សម្រាប់ការសងបំណុលនឹងទូទាត់ទៅតាមទំហំដីចម្ការកៅស៊ូគ្រួសារ ដែលមាននៅក្នុងកិច្ចព្រមព្រៀងពេលបច្ចុប្បន្ន ហើយដាក់ទៅក្នុងកិច្ចសន្យាថ្មី។
- In the new agreement, the debt payment has to be made based on the current size of family rubber farmland as indicated in the current agreement.

### ១.១.៤.-ការធានាសុវត្ថិភាពដីចម្ការកៅស៊ូគ្រួសារ

### 1.1.4.- Warranty of family rubber farmland

- ភាគីក្រុមហ៊ុនសន្យា និងធានាថាមិនធ្វើការដកហូតយកដីចម្ការកៅស៊ូគ្រួសារពីសហគមន៍ ក្នុងអំឡុងពេលនៃកិច្ចសន្យារវាងក្រុមហ៊ុន និងរាជរដ្ឋាភិបាលកម្ពុជាទេ លើកលែងតែករណីដែលរាជរដ្ឋាភិបាលធ្វើការដកហូតនូវសិទ្ធិសម្បទានដីសេដ្ឋកិច្ចពីក្រុមហ៊ុនវិញ។
- The **Company Party** promises and warrants that the company will not take family rubber farmland back from communities during the duration of ELC between Royal Government and company, unless the Royal Government withdraws the license of ELC from the company.
- បើថ្ងៃក្រោយក្រុមហ៊ុនផុតកិច្ចសន្យាដីសម្បទានសេដ្ឋកិច្ចជាមួយរាជរដ្ឋាភិបាលនោះក្រុមហ៊ុនក៏ផុតកាតព្វកិច្ចទាំងឡាយដែលមានចែងក្នុងកិច្ចព្រមព្រៀងរវាងក្រុមហ៊ុនជាមួយសហគមន៍ដូចគ្នា។
- If the agreement between the company and the Royal Government expires, all obligations under the agreement between the company and the community, will expire too.

### ១.១.៥.-កិច្ចសន្យាជួលដីចម្ការកៅស៊ូគ្រួសារ

### 1.1.5.- Leasing of family rubber farmland

- ភាគីក្រុមហ៊ុននិងភាគីសហគមន៍ព្រមព្រៀងធ្វើកិច្ចសន្យាចម្ការកៅស៊ូគ្រួសារថ្មី
- The **Company Party** and **Community Party** agree to have a new agreement on family rubber farmland.



first class
in pursuit of speed and quality

**First-Class Solutions Ltd.**, registered under No. Co. 13113/09P with the Ministry of Commerce of the Kingdom of Cambodia

#12 Street 222, Phnom Penh, Cambodia
+855 23 214 142 / 12 925 789 / 18 960 748 / 78 567 863
fcinfo@firstclass.com.kh | www.firstclass.com.kh
(IMG2021)

Phnom Penh, September 17, 2021
*This is to certify that the translation correctly corresponds to all the essential particulars of the attached document. It does not establish the authenticity of the original document or the correctness of the contents herein.*

FIRST-CLASS SOLUTIONS LTD.

CHAN Sopheap, Translation PM; CHAN Kruy, CEO

- ភាគីក្រុមហ៊ុននឹងផ្ដល់សេចក្ដីព្រាងកិច្ចសន្យាកៅស៊ូគ្រួសារថ្មីនៅខែមិថុនា ឆ្នាំ២០២២ ដល់តំណាងសហគមន៍ដែលចូលរួមក្នុងការសម្រុះសម្រួល ។
- The **Company Party** shall provide the draft new agreement to the community who have names in the mediation process in June 2022.
- ក្នុងករណីនេះ ភាគីសហគមន៍មានសិទ្ធិយកសេចក្ដីព្រាងនៃកិច្ចសន្យាចម្ការកៅស៊ូគ្រួសារថ្មីទៅធ្វើការពិភាក្សាជាមួយមេធាវី ភាគីពាក់ព័ន្ធ និងអង្គការមិនមែនរដ្ឋាភិបាល និងធ្វើការផ្ដល់យោបល់របស់សហគមន៍ត្រឡប់មកក្រុមហ៊ុនវិញ ដើម្បីក្រុមហ៊ុនធ្វើការសិក្សា និងពិភាក្សាគ្នាស្វែងរកចំណុចរួមរវាងសហគមន៍ និងក្រុមហ៊ុនដែលអាចឈានទៅរកការព្រមព្រៀងគ្នា នាពេលអនាគត។
- In this case, the **Community Party** has the rights to discuss about the draft agreement, which will be developed by the company, with lawyers, relevant stakeholders, and NGOs and provide feedback to the company in order to improve the agreement which is reached by both parties.

### ១.១.៦.-ចុះបញ្ជីដីចម្ការកៅស៊ូគ្រួសារ

### 1.1.6.- Registration of family rubber farmland

- ក្នុងករណីរាជរដ្ឋាភិបាលយល់ព្រមបន្តកិច្ចសន្យាសម្បទានដីសេដ្ឋកិច្ចជាមួយក្រុមហ៊ុននាពេលអនាគត ក្រុមហ៊ុនរក្សាសិទ្ធិជូនសហគមន៍ ធ្វើការសម្រេចចិត្តក្នុងការបន្តកិច្ចសន្យាចម្ការកៅស៊ូគ្រួសារជាមួយក្រុមហ៊ុន ។
- In case the Royal Government agrees to continue the agreement of ELC to the company in the future, the community has the right to make decision regarding the continuity to the same agreement between the company and the community.
- បន្ទាប់ពីបញ្ចប់កិច្ចសន្យាសម្បទានដីសេដ្ឋកិច្ច ក្នុងករណីភាគីសហគមន៍មិនចង់បន្តកិច្ចសន្យាជាមួយក្រុមហ៊ុននាពេលអនាគត សហគមន៍អាចយកដីចម្ការកៅស៊ូគ្រួសារដែលបានគ្រប់គ្រងនាពេលកន្លងមកទៅស្នើសុំចុះបញ្ជីជាមួយរាជរដ្ឋាភិបាលជាដីសមូហភាពបាន។ ក្នុងករណីនេះ កិច្ចសន្យាចម្ការកៅស៊ូគ្រួសាររវាងសហគមន៍ និងក្រុមហ៊ុននឹងត្រូវបញ្ចប់ រាល់កាតព្វកិច្ចទាំងឡាយរបស់ក្រុមហ៊ុនត្រូវបញ្ចប់ដូចគ្នា។
- After the end of the ELC contract, In case the **Community Party** does not want to continue the agreement with company, the community can register family rubber farmland with the government as communal land. In this case, the rubber agreement between the community families and the company will be terminated and all obligations of the company will be ended.

### ១.១.៧.-ករណីបំណុល

### 1.1.7.- Debt

- ភាគីក្រុមហ៊ុនព្រមព្រៀងមិនធ្វើការទាមទារនូវប្រាក់ថ្លៃឈ្នួលដីសម្រាប់រយៈកាលកន្លងមក និងដែលត្រូវបានបង់ជូនទៅរាជរដ្ឋាភិបាល ចំនួន ប្រាំមួយ (៦)ដុល្លារក្នុងមួយហិកតា (ដែលតម្លៃនេះអាចមានការផ្លាស់ប្ដូរដោយរាជរដ្ឋាភិបាល) ពីសហគមន៍ ប៉ុន្តែភាគីក្រុមហ៊ុនសុំសរសេរអំពីប្រាក់ឈ្នួលដីចំនួនប្រាំមួយ(៦)ដុល្លារក្នុងមួយហិកតាពីសហគមន៍នៅក្នុងកិច្ចសន្យាចម្ការកៅស៊ូគ្រួសារថ្មីនាពេលអនាគតដដែលដើម្បីឱ្យស្របច្បាប់ និងការពារនូវការចោទប្រកាន់ពីរាជរដ្ឋាភិបាលមកលើក្រុមហ៊ុនថាធ្វើការលក់ដីសម្បទានឱ្យប្រជាពលរដ្ឋ។
- The **Company Party** agrees not to claim the previously-incurred land rental fee from the community and which the company has paid to the government at USD6 (six USD) per hectare



first class
In pursuit of speed and quality

**First-Class Solutions Ltd.**, registered under No. Co. 13113/09P with the Ministry of Commerce of the Kingdom of Cambodia

#12 Street 222, Phnom Penh, Cambodia
+855 23 214 142 / 12 925 789 / 18 960 748 / 78 567 863
fcinfo@firstclass.com.kh | www.firstclass.com.kh
*(IMG2021)*

Phnom Penh, September 17, 2021
*This is to certify that this translation correctly corresponds to all the essential particulars of the attached document. It does not establish the authenticity of the original document or the correctness of the contents herein.*

ហ្វឺស-ក្លាស សូលូសិន ឯ.ក
FIRST-CLASS SOLUTIONS LTD.
ភ្នំពេញ

**CHAN Sophean**, Translation PM, **LIM Kruy**, CEO

per year, (this fee can be subject to changes from the royal government of Cambodia). But the **Company Party** requests to write the rental fee of 6USD (six USD) per hectare per year into the new agreement in order to follow the laws and to prevent the company from allegation by the Royal Government that the company sells the land to the community.

- ភាគីទាំងពីរនឹងពិភាក្សាអំពីការទូទាត់បំណុល និងពេលវេលានៃការទូទាត់បំណុលរបស់សហគមន៍ជូនមកក្រុមហ៊ុន នៅពេលទទួលបានសេចក្តីព្រាងកិច្ចសន្យាចម្ការកៅស៊ូគ្រួសារថ្មី ហើយដាក់បញ្ចូលទៅក្នុងកិច្ចសន្យាចម្ការកៅស៊ូគ្រួសារថ្មី ។
- Both parties will discuss on the mode and schedule of debt payment from the community to the company after receiving the new draft agreement and all points will be embedded in the new agreement.

១.១.៨.-ការទិញលក់ជ័រកៅស៊ូ

**1.1.8.- Buying and selling of rubber**

- ភាគីក្រុមហ៊ុនយល់ព្រមទិញជ័រកៅស៊ូពីសហគមន៍តាមតម្លៃទីផ្សារ ឬតាមតម្លៃដែលចេញដោយក្រសួងកសិកម្ម រុក្ខាប្រម៉ាញ់ និងនេសាទ ឬក្រសួងពាណិជ្ជកម្ម។
- The **Company Party** agrees to buy rubber from the community based on the market price or the prices as announced from time to time by the Ministry of Agriculture, Forestry and Fisheries (MAFF) as well as by the Ministry of Commerce (MoC).

- ភាគីសហគមន៍មានសិទ្ធិក្នុងការលក់ជ័រកៅស៊ូឱ្យក្រុមហ៊ុនតាមតម្លៃដែលក្រុមហ៊ុនបញ្ជាក់ជូនខាងលើ ក្នុងករណីសហគមន៍មិនពេញចិត្តចំពោះតម្លៃរបស់ក្រុមហ៊ុនដាក់ជូន សហគមន៍មានសិទ្ធិលក់ជ័រកៅស៊ូទៅឱ្យឈ្មួញដទៃឬភាគីតតិយជន (ភាគីទីបី) ផ្សេងទៀតបាន។
- The **Community Party** has the right to sell rubber to the company based on the abovementioned price, if the community does not agree on the prices offered by the company, the community has the right to sell rubber to other buyers or third parties.
- ភាគីសហគមន៍ និងភាគីក្រុមហ៊ុនព្រមព្រៀងយកចំណុចនេះ សរសេរទៅក្នុងកិច្ចសន្យាចម្ការកៅស៊ូគ្រួសារថ្មី។
- The **Community Party** and **Company Party** agree to write all these points into the new agreement on family rubber farmland.

១.២.-ភាគីសហគមន៍យល់ព្រមធ្វើការជ្រើសរើស អ្នកតំណាង៥ (ប្រាំ) នាក់ពី ៤ភូមិ(ភូមិពូចា ភូមិពូរាំង ភូមិពូលុ និងភូមិពូទឺត) សម្រាប់ការចូលរួមចរចាជាមួយក្រុមហ៊ុនលើសេចក្តីព្រាងកិច្ចសន្យាចម្ការកៅស៊ូគ្រួសារថ្មីជាមួយក្រុមហ៊ុន និងការងារផ្សេងៗទៀតដូចមានចែងក្នុងចំណុច ១.១ខាងលើ។

**1.2.-** The **Community Party** agrees to select five (5) representatives from four villages namely Pu Char, Pu Raing, Pu Lu and Pu Teut to participate in the negotiation with the company about the new draft agreement as stated in 1.1 above.

- អ្នកតំណាងទាំង៥ (ប្រាំ) នាក់ ត្រូវមានលិខិតផ្តល់ស្នាមមេដៃតែងតាំងពីសមាជិកចម្ការកៅស៊ូគ្រួសារទាំង៤ភូមិ។



**First-Class Solutions Ltd.**, registered under No. Co. 13113/09P with the Ministry of Commerce of the Kingdom of Cambodia

first class
in pursuit of speed and quality

#12 Street 222, Phnom Penh, Cambodia
+855 23 214 142 / 12 925 789 / 18 960 748 / 78 567 863
fcinfo@firstclass.com.kh | www.firstclass.com.kh
(IMG2021)

Phnom Penh, September 17, 2021

*This is to certify that this translation correctly corresponds to all the essential particulars of the original document. It does not establish the authenticity of the original document or the correctness of the contents herein.*

FIRST-CLASS SOLUTIONS LTD

**CHAN Sopheap**, Translation PM | **LIM Kruy**, CEO

- The five (5) representatives have to obtain official nomination and thumbprints from their members of the four villages.
- ភាគីសហគមន៍នឹងផ្តល់នូវលិខិតស្តីពីការជ្រើសរើសតំណាងទាំង៥ (ប្រាំ) នាក់ខាងលើជូនទៅក្រុមហ៊ុន។
- The **Community Party** will give official letter about the selection of the 5 (five) representatives to the company.

**ប្រការ ២.- ឯកសារឧបសម្ព័ន្ធនៃកិច្ចព្រមព្រៀងនេះ**

**Article 2.- Annexes to the agreement**

ភាគីសហគមន៍ និងភាគីក្រុមហ៊ុន យល់ព្រម និងឯកភាពគ្នាទទួលយកនូវឯកសារមួយចំនួនដែលជាឧបសម្ព័ន្ធនៃកិច្ចព្រមព្រៀងសះជា ដូចខាងក្រោមនេះ៖

The **Community Party** and the **Company Party** agree to recognize the following documents as annexes in the agreements:

- បញ្ជីរាយនាមនៃកិច្ចព្រមព្រៀងរវាងក្រុមហ៊ុន និងអ្នកដាំ
- List of the agreements between company and growers
- បញ្ជីរាយនាមនៃវិសោធនកម្មស្តីពីកិច្ចព្រមព្រៀងអំពីការផ្ទេរសិទ្ធិ
- List of the amendment of the agreements on transferred authorization
- បញ្ជីរាយនាមនៃវិសោធនកម្មស្តីពីការផ្លាស់ប្តូរទីតាំង
- List of the amendment on the changing location of the family rubber farmland
- បញ្ជីរាយនាមនៃទិន្នន័យទំហំដីចម្ការកៅស៊ូគ្រួសាររបស់សហគមន៍ភូមិពូចា ជាមួយក្រុមហ៊ុនវ៉ារ៉ាណាស៊ី
- List of data related to size of family rubber farmland of Pu Char village with Varanasi company.
- ផែនទីបង្ហាញទីតាំងដីចម្ការកៅស៊ូគ្រួសាររបស់សហគមន៍ភូមិពូចា ជាមួយក្រុមហ៊ុនវ៉ារ៉ាណាស៊ី
- Maps showing the locations of family rubber farmland of Pu Char village with Varanasi company.
- បញ្ជីឈ្មោះគ្រួសារដែលបានកាន់កាប់ដីចម្ការកៅស៊ូគ្រួសាររបស់សហគមន៍ភូមិពូចា ជាមួយក្រុមហ៊ុនវ៉ារ៉ាណាស៊ី។
- List of the families who occupy the family rubber farmland of Pu Char village with Varanasi company.
- លិខិតប្រគល់សិទ្ធិជាអ្នកតំណាងលើករណីដីចម្ការកៅស៊ូគ្រួសាររបស់ភូមិពូចា ចុះថ្ងៃទី ២០ ខែកុម្ភៈ ឆ្នាំ ២០១៧។
- Letter of authorization as representatives for family rubber farmland of Pu Char village dated 20 February 2017.
- ឯកសារមួយចំនួនផ្សេងទៀតដែលមានទំនាក់ទំនង ឬពាក់ព័ន្ធនឹងករណីដីចម្ការកៅស៊ូគ្រួសាររបស់ភូមិពូចា និងក្រុមហ៊ុនវ៉ារ៉ាណាស៊ី។
- Other relevant documents related to family rubber farmland of Pu Char village with Varanasi company.

**ប្រការ ៣.-ភារកិច្ច និងការធានារបស់ភាគីសហគមន៍**

**Article 3.- Obligations and Warranties of the Community Party**



first class
in pursuit of speed and quality

First-Class Solutions Ltd., registered under No. Co. 13113/09P with the Ministry of Commerce of the Kingdom of Cambodia

#12 Street 222, Phnom Penh, Cambodia
+855 23 214 142 / 12 925 789 / 18 960 748 / 78 567 863
fcinfo@firstclass.com.kh | www.firstclass.com.kh
(IMG2021)

Phnom Penh, September 17, 2021
*This is to certify that the translation correctly corresponds to all the essential particulars of the attached document. It does not establish the authenticity of the original document or the correctness of the contents herein.*

FIRST-CLASS SOLUTIONS LTD.

CHAN Sophea, Translation PM, LIM Kruy, CEO

៣.១- ភាគីសហគមន៍ ត្រូវធានាថាខ្លួនមានសិទ្ធិស្របច្បាប់នៅក្នុងការចុះកិច្ចព្រមព្រៀងនេះ និងមានកាតព្វកិច្ចធានាថាមិនធ្វើការរំខានចំពោះករណីដែលបានដោះស្រាយរួចហើយរបស់ខ្លួនចំពោះភាគីក្រុមហ៊ុនម្តងទៀតទេ។

3.1- **The Community Party** shall warrant that it has the legal right to enter into this Agreement and is obliged to ensure that it will not cause further disturbance to **the Company Party** for the case resolved.

៣.២- ភាគីសហគមន៍ធានាថាខ្លួននឹងប្រាប់ទៅសមាជិកសហគមន៍របស់ខ្លួន និងកូនចៅជំនាន់ក្រោយរបស់សហគមន៍ឱ្យគោរពនូវប្រការនានាដែលមានចែងក្នុងកិច្ចព្រមព្រៀងនេះ។

3.2- **The Community Party** warrants that it will inform its community members and the younger generations of the community and cause them to honor all the provisions of this Agreement.

៣.៣- ភាគីសហគមន៍មានកាតព្វកិច្ចអនុវត្តនូវគ្រប់ប្រការទាំងអស់ដូចមានចែងនៅក្នុងកិច្ចព្រមព្រៀងនេះ ឱ្យស្របតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា។

3.4- **The Community Party** is obliged to carry out all the provisions of this Agreement in accordance with the laws of the Kingdom of Cambodia.

**ប្រការ ៤.-ភាតព្វកិច្ច និងការធានារបស់ភាគីក្រុមហ៊ុន**

**Article 4.- Obligations and Warranties of the Company Party**

៤.១- ភាគីក្រុមហ៊ុន សន្យានឹងមិនធ្វើការឈូសឆាយ ឬប៉ះពាល់លើដីចម្ការកៅស៊ូគ្រួសារទាំងអស់ ដូចមានចែងក្នុងប្រការ ១ និងប្រការ ២ ខាងលើទៅថ្ងៃអនាគតនោះទេ។

4.1- **The Company Party** covenants that it will not clear or do anything to the family rubber farmland as stated in Article 1 and 2 above in the future.

៤.២- ភាគីក្រុមហ៊ុនធានាថាទោះបីថ្ងៃក្រោយមានការប្រែប្រួលអ្នកដឹកនាំ ឬធ្វើការផ្ទេរនៅសិទ្ធិលើការគ្រប់គ្រងនៃដីសម្បទាននេះទៅឲ្យក្រុមហ៊ុនផ្សេង ឬតតីយជន (ភាគីទីបី) ក៏ដោយ ក្រុមហ៊ុននឹងបញ្ចូលនូវឯកសារនៃកិច្ចព្រមព្រៀងនេះទៅក្នុងកិច្ចសន្យាសម្បទានបន្ត ឬកិច្ចសន្យាលក់សិទ្ធិសម្បទាននោះ។

4.2- **The Company Party** warrants that regardless of any future change in the management or the transfer of management rights on the concession to other companies or third parties, the company will incorporate this agreement document in the transferred Concession Agreement or the contract for the sale of the concession rights.

៤.៣- ភាគីក្រុមហ៊ុនមានកាតព្វកិច្ចអនុវត្តនូវគ្រប់ប្រការទាំងអស់ដូចមានចែងនៅក្នុងកិច្ចព្រមព្រៀងនេះ ឱ្យស្របតាមច្បាប់នៃ ព្រះរាជាណាចក្រកម្ពុជា។

4.3- **The Company Party** is obliged to carry out all the provisions of this Agreement in accordance with the laws of the Kingdom of Cambodia.

**ប្រការ៥.- ការមិនគោរព ឬបំពានកិច្ចព្រមព្រៀង**

**Article 5.- Default or Violations of Agreement**



first class
in pursuit of speed and quality

**First-Class Solutions Ltd.**, registered under No. Co. 13113/09P with the Ministry of Commerce of the Kingdom of Cambodia

#12 Street 222, Phnom Penh, Cambodia
+855 23 214 142 / 12 925 789 / 18 960 748 / 78 567 863
fcinfo@firstclass.com.kh | www.firstclass.com.kh
(IMG2021)

Phnom Penh, September 17, 2021
*This is to certify that this translation correctly corresponds to all the essential particulars of the attached document. It does not establish the authenticity of the original document or the correctness of the contents therein.*

FIRST-CLASS SOLUTIONS

CHAN Sopheap, Translation PM   DAN TIM Kruy, CEO

៥.១- ក្នុងករណីភាគីសហគមន៍បានបំពាន ឬមិនគោរពតាមបញ្ញត្តិនៃកិច្ចព្រមព្រៀងនេះ ភាគីសហគមន៍សុខចិត្តទទួលខុសត្រូវ តាមច្បាប់នៃព្រះរាជណាចក្រកម្ពុជា ដែលមានជាធរមាន។

5.1- In the event that the **Community Party** has violated or failed to comply with the provisions of this Agreement, the **Community Party** undertakes to be held responsible before the applicable laws of the Kingdom of Cambodia.

៥.២- ក្នុងករណីភាគីក្រុមហ៊ុនបានបំពាន ឬមិនគោរពតាមបញ្ញត្តិនៃកិច្ចព្រមព្រៀងនេះ ភាគីក្រុមហ៊ុនសុខចិត្តទទួលខុសត្រូវ តាមច្បាប់នៃព្រះរាជណាចក្រកម្ពុជា ដែលមានជាធរមាន។

5.2- In the event that **the Company Party** has violated or failed to comply with the provisions of this Agreement, **the Company Party** undertakes to be held responsible before the applicable laws of the Kingdom of Cambodia.

៥.៣- ក្នុងករណីដែលភាគីណាមួយដែលបំពាននៃកិច្ចព្រមព្រៀងនេះ ហើយបណ្តាលឲ្យមានការខូចខាតកើតឡើងទាំងផ្នែករូបីយវត្ថុ (សាច់ប្រាក់ឬ លុយ) ផ្លូវចិត្ត និងផលប្រយោជន៍ផ្សេងៗរបស់ភាគីម្ខាងទៀតនោះភាគីដែលរំលោភកិច្ចព្រមព្រៀងនេះនឹងទទួលខុសត្រូវចំពោះមុខច្បាប់។

5.3- In the event that any party violates this Agreement resulting in damage both monetarily (cash or money) and emotionally and to other interests of the other party, the violating party shall assume legal responsibility.

៥.៤- ភាគីណាមួយក៏ដោយដែលរំលោភបំពាននៃកិច្ចព្រមព្រៀងនេះ ត្រូវធានាសងចំពោះការខូចខាតទាំងឡាយដែលកើតមានចំពោះភាគីម្ខាងទៀត លើរាល់ការចំណាយនៃការខូចខាត ថ្លៃសេវាផ្សេងៗ រួមទាំងថ្លៃមេធាវីដែលអាចកើតមានឡើងដោយសារការរំលោភបំពានកិច្ចព្រមព្រៀងនេះ។

5.4- Any party that violates this Agreement shall be liable for paying damages incurred by the other party for all costs of damages, fees including attorneys' fees that may incur as a result of the breach of this Agreement.

## ប្រការ ៦.-នីតិវិធីនៃការដោះស្រាយវិវាទសម្រាប់ការរំលោភបំពានលើការមិនគោរពកិច្ចព្រមព្រៀង

## Article 6.- Procedures for resolving disputes for violation or breach the Agreement

៦.១- ក្នុងករណីមានវិវាទកើតឡើងភាគីនឹងធ្វើការចរចាគ្នាដោយសន្តិវិធីជាមុនសិន តាមរយៈការជួបពិភាក្សាគ្នាដោយផ្ទាល់មាត់ ឬជាការជូនដំណឹងជាលាយលក្ខណ៍អក្សរដើម្បីធ្វើការដោះស្រាយ ក្នុងរយៈពេល៦០ថ្ងៃ។

6.1- In the event of any dispute, the parties shall first conduct a peaceful negotiation through personal discussions or a written notices for resolution in the duration of 60 days.

៦.២-ក្នុងករណីការចរចាគ្នាមិនបានសម្រេច ភាគីទាំងពីរឯកភាព និងសុខចិត្តយកវិវាទនេះដាក់ជូនតុលាការនៃព្រះរាជាណាចក្រកម្ពុជាជាអ្នកដោះស្រាយ។

6.2- Should the negotiation fail, the two parties agree and accept to submit the dispute in question to the courts of the Kingdom of Cambodia for a decision.



first class
in pursuit of speed and quality

First-Class Solutions Ltd., registered under No. Co. 13113/09P with the Ministry of Commerce of the Kingdom of Cambodia

#12 Street 222, Phnom Penh, Cambodia
+855 23 214 142 / 12 925 789 / 18 960 748 / 78 567 863
fcinfo@firstclass.com.kh | www.firstclass.com.kh
(IMG2021)

Phnom Penh, September 17, 2021
*This is to certify that this translation correctly corresponds to all the essential particulars of the attached document. It does not establish the authenticity of the original document or the correctness of the contents herein.*

FIRST-CLASS SOLUTIONS

CHAN Sophеap, Translation PM    KIM Kruy, CEO

## ប្រការ ៧.- ឆន្ទៈ និងសមត្ថភាពរបស់ភាគី

**Article 7.-Willingness and Capacity of Parties**

៧.១- ភាគីទាំងពីរមានឆន្ទៈរួមគ្នាដើម្បីបង្កើតកិច្ចព្រមព្រៀងនេះឡើងដោយគ្មានការបង្ខិតបង្ខំឬការគំរាមកំហែងពីភាគីណាមួយនោះឡើយ។

7.1- Both parties are willing to enter into this Agreement without coercion or threat from any party.

៧.២- ភាគីទាំងពីរបានអាន បានស្តាប់យល់ និងមានសមត្ថភាពយល់ដឹងនូវខ្លឹមសារបានគ្រប់ប្រការទាំងអស់ដូចដែលមានចែងក្នុងកិច្ចព្រមព្រៀងនេះ ដោយសន្យាថានឹងអនុវត្តគ្រប់ប្រការទាំងអស់នៃកិច្ចព្រមព្រៀងនេះឱ្យបានត្រឹមត្រូវ និងស្របតាមច្បាប់។

7.2- Both parties have read, been read out and have competence to fully understand all the provisions hereof, undertaking to duly carry out all the provisions of this Agreement in accordance with the law.

## ប្រការ ៨.-ច្បាប់នៃកិច្ចព្រមព្រៀង និង ភាសាដែលប្រើក្នុងកិច្ចព្រមព្រៀង

**Article 8.- Counterpart, language used in the agreement**

៨.១-ភាគីទាំងអស់ ឯកភាពគ្នាទទួលយកច្បាប់នៃព្រះរាជាណាចក្រកម្ពុជាជាច្បាប់នៃការអនុវត្តនិងការបកស្រាយកិច្ចព្រមព្រៀងនេះជាគោល។

8.1- All parties agree that the laws of the Kingdom of Cambodia shall be the principal laws governing the performance and interpretation of this Agreement.

៨.២-កិច្ចព្រមព្រៀងនេះត្រូវធ្វើឡើងជាភាសាខ្មែរ និងមានការបកប្រែជាភាសាអង់គ្លេស ចំនួន ០៥(ប្រាំ)ច្បាប់ដើមនៅក្នុងភាសានីមួយៗ ហើយគ្រប់ច្បាប់ទាំងនេះត្រូវចាត់ទុកជាលិខិតតូបករណ៍ ឬលិខិតផ្លូវការតែមួយ និង ដូចៗគ្នា។ ក្នុងករណីមានភាពខុសគ្នារវាងអត្ថបទជាភាសាខ្មែរ និងអត្ថបទជាភាសាអង់គ្លេស ភាសាខ្មែរត្រូវប្រើជាអត្ថបទគោលក្នុងការបកស្រាយកិច្ចព្រមព្រៀងនេះ។

8.2- This agreement shall be made in Khmer and accompanied with English translation into 05 (five) originals of each language, all of which taken together shall constitute one and the same instrument or official instrument. In the event of any inconsistency between Khmer and English versions of the Agreement, the Khmer version of the Agreement shall be the prevailing text in the interpretation of this Agreement.

## ប្រការ ៩.-អវសានប្បញ្ញត្តិនៃកិច្ចព្រមព្រៀង

**Aritcle 9.- Final provisions of the Agreement**

៩.១- កិច្ចព្រមព្រៀងនេះត្រូវបានធ្វើឡើងជាភាសាខ្មែរនិងអង់គ្លេស ចំនួន០៥(ប្រាំ) ច្បាប់ដើមក្នុងមួយភាសាដែលមានតម្លៃគតិយុត្តស្មើគ្នា និងដូចគ្នា ហើយត្រូវរក្សាទុកនៅភាគីសហគមន៍ចំនួន ០១(មួយ)ច្បាប់ដើម, ភាគីក្រុមហ៊ុន ចំនួន០១ (មួយ)ច្បាប់ដើម អ្នកសម្រុះសម្រួលចំនួន០១(មួយ)ច្បាប់ដើមតម្កល់នៅសាលា



first class
in pursuit of speed and quality

**First-Class Solutions Ltd.**, registered under No. Co. 13113/09P with the Ministry of Commerce of the Kingdom of Cambodia

#12 Street 222, Phnom Penh, Cambodia
+855 23 214 142 / 12 925 789 / 18 960 748 / 78 567 863
fcinfo@firstclass.com.kh | www.firstclass.com.kh
*(IMG2021)*

Phnom Penh, September 17, 2021
*This is to certify that this translation correctly corresponds to all the essential particulars of the attached document. It does not establish the authenticity of the original document or the correctness of the contents herein.*

FIRST-CLASS SOLUTIONS

CHAN Sophan, Translation PM | LIM Kruy, CEO

ស្រុកពេជ្រាដា ចំនួន ០១(មួយ)ច្បាប់ និង ០១(មួយ)ច្បាប់ដើម សម្រាប់ភាគីសហគមន៍រៀបចំបែបបទស្នើសុំចុះបញ្ជីដីសមូហភាពរបស់សហគមន៍ភូមិពូចា។

9.1- This Agreement is made in Khmer and English into 05 (five) originals of the same and equal legal force and effect and 01 (one) original of which shall be retained with the Community Party, the Company Party, mediator, filed at Pichreada district Hall and with the Community Party for completion of the application form for registration of Pu Char village communal land, respectively.

៩.២- គ្រប់ភាគីទាំងអស់ត្រូវបានចងកាតព្វកិច្ចចំពោះលក្ខខណ្ឌនៅក្នុងកិច្ចព្រមព្រៀងនេះនិងត្រូវចុះហត្ថលេខាឬផ្តិតស្នាមមេដៃស្តាំលើកិច្ចព្រមព្រៀងដើម្បីជាសក្ខីភាព ឬការបញ្ជាក់នៃការចូលរួមរបស់ខ្លួន។

9.2- All parties are bound by the terms of this Agreement and shall affix their signatures or right thumbprints on the Agreement as testimony or in the acknowledgement of their acceptance.

៩.៣- កិច្ចព្រមព្រៀងនេះមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខា ឬផ្តិតស្នាមមេដៃនេះតទៅ។

9.3- This agreement is effective from the date of signing or affixing thumbprints.

| ភាគីសហគមន៍<br>Community party | ភាគីក្រុមហ៊ុន<br>Company Party |
| --- | --- |
| ~~លោកប្រាក់ ប៊ុនញ៉ុង~~ លោកព្ញើស ញែប លោកព្រុត ថា<br>~~Mr. Prak Bonnhong~~ Mr. PcheusNheb Mr. Prut Tha<br>Brop Tuch | VARANASI Co., Ltd.<br>[redacted]<br>ក្រុមហ៊ុនវ៉ារ៉ាណាស៊ី<br>Varanasi Company |



**First-Class Solutions Ltd.**, registered under No. Co. 13113/09P with the Ministry of Commerce of the Kingdom of Cambodia

first class
in pursuit of speed and quality

#12 Street 222, Phnom Penh, Cambodia
+855 23 214 142 / 12 925 789 / 18 960 748 / 78 567 863
fcinfo@firstclass.com.kh | www.firstclass.com.kh
(IMG2021)

Phnom Penh, September 17, 2021
*This is to certify that this translation correctly corresponds to all the essential particulars of the attached document. It does not establish the authenticity of the original document or the correctness of the contents therein.*

CHAN Sophea, Translation PM | LIM Kruy, CEO

មេធាវីរបស់ភាគីសហគមន៍

Attorney at law of the community

| | |
|---|---|
| ធឿង ពុទ្ធារិទ្ធ | រុន សារ៉ាយ |
| **Thoeung Puthearith** | **Run Saray** |

## សាក្សី

## Witnesses

| តំណាងខាងអង្គការសហប្រជាជាតិ | តំណាងចាស់ទុំភូមិពូចា | | តំណាងអាជ្ញាធរស្រុកពេជ្រាដា |
|---|---|---|---|
| UN-OHCHR Representative | Representatives of the elders Pu Char | | Pichreada District Authority |
| [redacted] | ពើន គី | ត្រាំង ស៊ន | ខាំ ផងជា |
| | PoeurnKoe | Traing Sorn | Kham Phangchea |



first class
in pursuit of speed and quality

**First-Class Solutions Ltd.**, registered under No. Co. 13113/09P with the Ministry of Commerce of the Kingdom of Cambodia

#12 Street 222, Phnom Penh, Cambodia
+855 23 214 142 / 12 925 789 / 18 960 748 / 78 567 863
fcinfo@firstclass.com.kh | www.firstclass.com.kh
*(IMG2021)*

Phnom Penh, September 17, 2021
*This is to certify that this translation correctly corresponds to all the essential particulars of the attached document. It does not establish the authenticity of the original document or the correctness of the contents therein.*

**CHAN Sophiap**, Translation PM [illegible] Kruy, CEO

អ្នកសម្រុះសម្រួល
**Mediator**

លោក ប៉ូច សោភ័ណ
Mr. Poch Sophorn
ក្រុមសម្រុះសម្រួលឯករាជ្យ
Independent Mediation Team

បានឃើញ និងបញ្ជាក់ថា
**Seen and certified that**
ភាគីទាំងពីរពិតជាបានព្រមព្រៀងគ្នាតាមកិច្ចព្រមព្រៀង
និងបានផ្តិតមេដៃចំពោះមុខពិតប្រាកដមែន។
Both Parties have agreed to the Agreement and affixed their thumbprints in my presence.
អាជ្ញាធរឃុំប៊ូស្រា
**Authority of Busra commune**

ឃុំ ប៊ូស្រា
យើត_សារីង



first class
in pursuit of speed and quality

**First-Class Solutions Ltd.**, registered under No. Co. 13113/09P with the Ministry of Commerce of the Kingdom of Cambodia

#12 Street 222, Phnom Penh, Cambodia
+855 23 214 142 / 12 925 789 / 18 960 748 / 78 567 863
fcinfo@firstclass.com.kh | www.firstclass.com.kh
*(IMG2021)*

Phnom Penh, September 17, 2021
*This is to certify that this translation correctly corresponds to all the essential particulars of the original document. It does not establish the authenticity of the original document or the correctness of the contents herein.*

FIRST-CLASS SOLUTIONS LTD

**CHAN Sopheap**, Translation PM **LIM Kruy**, CEO